# ព្រះរាជក្រម

នស/រកម/០៨០៩/០១៤

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃ សាធារណរដ្ឋឥណ្ឌាស្តីពីការផ្ទេរទណ្ឌិត ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភា លើកទី២ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៩ នាសម័យប្រជុំពេញអង្គ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :-

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌាស្តីពីការផ្ទេរទណ្ឌិត

**មាត្រា ១.-**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌា ស្តីពីការផ្ទេរទណ្ឌិត ដែលធ្វើនៅញូវដែលី នាថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៩

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស/រកម.០៨០៩.៧៣៦

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ហត្ថលេខា

លេខ: ៧៦៤ ច.ល

ស ខេង

ថតចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ២០០៩
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

ស៊ុន ជិនកេន

# កិច្ចព្រមព្រៀង

## រវាង

## រាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌា

## ស្តីអំពីការផ្ទេរទណ្ឌិត

---

រាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌាដែលហៅថា

"រដ្ឋហត្ថលេខី"

- **ដោយមានបំណង**ជួយសម្រួលការស្តារនីតិសម្បទាសង្គមនៃទណ្ឌិតទាំងឡាយ នៅក្នុងប្រទេសរបស់ជនទាំងនោះ និង
- **ដោយបានពិចារណាឃើញថា** គោលបំណងនេះអាចសម្រេចទៅបាន ដោយផ្តល់អោយជនបរទេស ទាំងឡាយដែលត្រូវបានផ្តន្ទាទោស និងដាក់ទោសរួចហើយ ដោយសារការប្រព្រឹត្តបទល្មើសឧក្រិដ្ឋរបស់ជននោះ ដើម្បីមានឱកាសទៅទទួលទោសនៅក្នុងសង្គមរបស់ខ្លួន ។

**បានព្រមព្រៀងដូចតទៅ :**

### មាត្រា ១

### និយមន័យ

**សំរាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ :**

ក- **"ការវិនិច្ឆ័យ"** មានន័យថា ជាសេចក្តីសំរេច ឬ ជាដីកាបង្គាប់របស់តុលាការ ឬ របស់សាលាជំរះក្តី ដែលកំណត់ការដាក់ទណ្ឌកម្ម ។

ខ- **"រដ្ឋទទួល"** មានន័យថា ជារដ្ឋដែលមានទណ្ឌិតអាចត្រូវបានផ្ទេរ ឬ ត្រូវបានផ្ទេរ ដើម្បីឱ្យទណ្ឌិតនោះទទួលទោសបន្ត ។

គ- **"ការដាក់ទោស"** មានន័យថា ជាការដាក់ទណ្ឌកម្ម ឬ វិធានការណាមួយដែលពាក់ព័ន្ធដល់ការដក- ហូតសេរីភាពមានថេរវេលាកំណត់ ឬ ការដាក់ពន្ធនាគារអស់មួយជីវិតបង្គាប់ដោយតុលាការ ឬ សាលាជំរះក្តីក្នុងការអនុវត្តនីយុត្តាធិការព្រហ្មទណ្ឌរបស់ខ្លួន ។

ឃ- **"ទណ្ឌិត"** មានន័យថា ជាជនដែលកំពុងទទួលទោសឱ្យជាប់ពន្ធនាគារ ក្រោមដីកាបង្គាប់ដោយតុលាការព្រហ្មទណ្ឌ រួមមានតុលាការទាំងឡាយដែលត្រូវបង្កើតឡើងដោយច្បាប់សំរាប់រយៈពេលមួយ នៅក្នុងរដ្ឋហត្ថលេខី ។

ង- "រដ្ឋផ្ទេរ" មានន័យថា ជារដ្ឋដែលបានដាក់ទោសទៅលើជនដែលអាចនឹងត្រូវបានផ្ទេរ ឬ ត្រូវបានផ្ទេររួចហើយ ។

## មាត្រា ២

## គោលការណ៍ទូទៅ

១- ជនណាដែលបានកាត់ទោសនៅក្នុងទឹកដីនៃរដ្ឋភាគីមួយ អាចត្រូវបានផ្ទេរទៅកាន់ដែនដីនៃរដ្ឋភាគីមួយទៀត ស្របទៅតាមបទបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ដើម្បីឱ្យជននោះទទួលទោសដែលបានដាក់ចំពោះខ្លួន ។ ចំពោះរឿងនេះ ជននោះអាចបញ្ជាក់ជូនរដ្ឋជាអ្នកផ្ទេរ ឬ រដ្ឋជាអ្នកទទួល នូវបំណងរបស់ខ្លួនអំពីការស្នើសុំផ្ទេរ ក្រោមកិច្ចព្រមព្រៀងនេះ ។

២- ការផ្ទេរខ្លួន អាចត្រូវបានស្នើឡើងដោយទណ្ឌិតណាមួយ ដែលជាជនជាតិនៃរដ្ឋភាគី ឬ ដោយជនដទៃណាម្នាក់ដែលមានសិទ្ធស្នើសុំក្នុងនាមទណ្ឌិត ស្របទៅតាមច្បាប់នៃរដ្ឋភាគី ដោយដាក់ពាក្យស្នើសុំទៅកាន់រដ្ឋភាគី និងទៅតាមលំនាំដែលកំណត់ដោយរដ្ឋាភិបាលនៃរដ្ឋភាគី ។

## មាត្រា ៣

## លក្ខខណ្ឌនៃការផ្ទេរទណ្ឌិត

១- ទណ្ឌិតអាចត្រូវបានផ្ទេរយោងទៅតាមកិច្ចព្រមព្រៀងនេះ តាមតែលក្ខខណ្ឌដូចតទៅ:

ក- ទណ្ឌិតនោះជាសញ្ជាតិនៃរដ្ឋទទួល

ខ- ទណ្ឌិតនោះមិនត្រូវបានកាត់ទោសប្រហារជីវិត

គ- ការវិនិច្ឆ័យទោសរបស់តុលាការ ត្រូវបានចូលជាស្ថាពរ

ឃ- គ្មានការស៊ើបសួរ គ្មានការបើកសវនាការ ឬ នីតិវិធីណាផ្សេងទៀត ដែលត្រូវរង់ចាំយកមកអនុវត្តទៅលើទណ្ឌិត នៅក្នុងរដ្ឋជាអ្នកផ្ទេរ ។

ង- នៅពេលទទួលសំណើសុំផ្ទេរ ទណ្ឌិតត្រូវសល់ទោសយ៉ាងតិចបំផុត ៦ខែទៀត ឬ ត្រូវជាប់ពន្ធនាគារអស់មួយជីវិត

ច- សកម្មភាព ឬ ការខកខានមិនបានបំពេញកាតព្វកិច្ចដែលបណ្តាលអោយជាប់ទោសនៅក្នុងរដ្ឋផ្ទេរ គឺជាអំពើ ដែលនាំអោយមានទោសឧក្រិដ្ឋនៅក្នុងរដ្ឋទទួល ឬ អាចជាបទល្មើសព្រហ្មទណ្ឌ ប្រសិនបើប្រព្រឹត្តនៅក្នុងដែនដីរបស់រដ្ឋទទួល ។

ឆ- ទណ្ឌិតមិនត្រូវបានកាត់ទោសពីបទល្មើសដោយច្បាប់យោធា

ជ- ការផ្ទេរការឃុំឃាំងទណ្ឌិតទៅអោយរដ្ឋទទួល មិនត្រូវធ្វើអោយប៉ះពាល់ដល់អធិបតេយ្យភាព សន្តិសុខ ឬ ផលប្រយោជន៍ណាមួយរបស់រដ្ឋផ្ទេរឡើយ

ឈ- ការយល់ព្រមផ្ទេរត្រូវមានការឯកភាពពីទណ្ឌិតនោះ ឬ ពីជនណាផ្សេង ដែលជាតំណាងស្របច្បាប់ យោងទៅតាមច្បាប់នៃរដ្ឋហត្ថលេខីនោះ ក្នុងករណីដែលទណ្ឌិតមានបញ្ហាអាយុ ឬ បញ្ហាកាយសម្បទា ឬ ជម្ងឺសតិប្រសាទដែលរដ្ឋហត្ថលេខី គិតថាចាំបាច់ ហើយ

ញ- រដ្ឋផ្ទេរ និង រដ្ឋទទួលត្រូវឯកភាពគ្នាចំពោះការផ្ទេរ ។

២- ក្នុងករណីពិសេស រដ្ឋផ្ទេរ និង រដ្ឋទទួល ក៏អាចសម្រុះសម្រួលគ្នាដើម្បីធ្វើការផ្ទេរទណ្ឌិត ទោះបីជា ថេរវេលាដែលនៅសេសសល់ដើម្បីទទួលទោសមានរយៈពេលតិចជាង ៦ខែ ក៏ដោយ ។

## មាត្រា ៤

## ភាតព្វកិច្ចក្នុងការផ្តល់ព័ត៌មាន

១- ប្រសិនបើទណ្ឌិតបានសំដែងបំណងចំពោះរដ្ឋជាអ្នកកាត់ទោស ចង់អោយមានការផ្ទេររូបខ្លួន សមស្របតាមកិច្ចព្រមព្រៀងនេះ រដ្ឋផ្ទេរត្រូវបញ្ជូនព័ត៌មាន និង ឯកសារដូចខាងក្រោមនេះ ទៅអោយរដ្ឋទទួល លើកលែងតែរដ្ឋផ្ទេរ ឬ រដ្ឋទទួលបានសំរេចរួចទៅហើយថា គេមិនយល់ព្រម ចំពោះការផ្ទេរនោះទេ :

ក- ឈ្មោះ និង សញ្ជាតិ កាលបរិច្ឆេទ និង ទីកន្លែងកំណើតរបស់ទណ្ឌិត

ខ- អាស័យដ្ឋានរបស់ទណ្ឌិត ប្រសិនបើមាននៅក្នុងរដ្ឋទទួល

គ- របាយការណ៍ស្តីអំពីបទល្មើសដែលតម្រូវអោយដាក់ទណ្ឌកម្ម

ឃ- ប្រភេទ រយៈពេល និងកាលបរិច្ឆេទចាប់ផ្តើមនៃទោស

ង- ច្បាប់ចំលងនៃការវិនិច្ឆ័យដែលបញ្ជាក់ជាផ្លូវការ និង ច្បាប់ចំលងនៃបទប្បញ្ញត្តិរបស់ច្បាប់ពាក់ព័ន្ធ ដែលបានពោលយោងសំរាប់ផ្តន្ទាទោសទណ្ឌិត

ច- របាយការណ៍ផ្នែកវេជ្ជសាស្ត្រ សង្គម ឬព័ត៌មាននានាស្តីពីទណ្ឌិត ទៅតាមតម្រូវការដើម្បីចាត់ការចំពោះពាក្យសុំរបស់ទណ្ឌិត ឬដើម្បីធ្វើការសំរេចលើប្រភេទនៃការឃុំឃាំងចំពោះទណ្ឌិត ។

ឆ- ព័ត៌មានដទៃទៀតដែលរដ្ឋទទួល អាចនឹងបញ្ជាក់ថាខ្លួនត្រូវការសំរាប់គ្រប់ករណី ដើម្បីអាចពិចារណាពីលទ្ធភាពទទួលយកការផ្ទេរ និង ផ្តល់ដំណឹងអោយទណ្ឌិតបានដឹងអំពីផលវិបាកនៃការផ្ទេរ ដោយអនុលោមតាមច្បាប់របស់ខ្លួន

ជ- សំណូមពរស្នើសុំផ្ទេរខ្លួនរបស់ទណ្ឌិត ឬ របស់ជនដែលមានសិទ្ធលើកសំណើក្នុងនាមទណ្ឌិត អនុលោមតាមច្បាប់របស់រដ្ឋផ្ទេរ និង

ឈ- របាយការណ៍ដែលបញ្ជាក់ពីរយៈពេលផ្តន្ទាទោសដែលទណ្ឌិតបានបំពេញរួចហើយ រួមទាំងព័ត៌មានស្តីពីការឃុំឃាំងមុនពេលបើកសវនាការ ការបន្ធូរបន្ថយទោស ឬ កត្តាដទៃផ្សេងៗ ទាក់ទងដល់ការ

អនុវត្តន៍ សាលក្រម ។

២- ក្នុងគោលបំណងជួយដល់ការធ្វើសេចក្តីសំរេចលើសំណូមពរតាមកិច្ចព្រមព្រៀងនេះ រដ្ឋទទួលត្រូវ បញ្ជូនពត៌មាន និង ឯកសារដូចតទៅនេះទៅអោយរដ្ឋផ្ទេរ វៀរលែងតែរដ្ឋទទួល ឬ រដ្ឋផ្ទេរបានសំរេចរួចហើយថា នឹងមិនយល់ព្រមចំពោះការផ្ទេរនោះទេ :

ក- សេចក្តីរៀបរាប់ ឬ ឯកសារដែលបញ្ជាក់ថាទណ្ឌិតជាសញ្ជាតិរបស់រដ្ឋទទួល

ខ- ច្បាប់ចំលងនៃច្បាប់ពាក់ព័ន្ធរបស់រដ្ឋទទួលដែលចែងពីសកម្មភាព ឬការខកខានមិនបានបំពេញកាតព្វកិច្ច ដែលដោយសារហេតុផលនេះ ទើបមានការវិនិច្ឆ័យទោសនៅក្នុងរដ្ឋផ្ទេរ បើសកម្មភាព ឬ ការខកខានបំពេញកាតព្វកិច្ចនោះ ក៏ជាបទល្មើសយោងតាមច្បាប់របស់រដ្ឋទទួល ឬក៏អាចកំណត់ថាជាបទល្មើស ប្រសិនបើបានប្រព្រឹត្តនៅលើទឹកដីរបស់រដ្ឋទទួល

គ- សេចក្តីរៀបរាប់ពីអនុភាពរបស់ច្បាប់ ឬ បទបញ្ញត្តិដែលទាក់ទងនឹងរយៈពេលនិងការអនុវត្តន៍សាលក្រមនៅក្នុងរដ្ឋទទួលបន្ទាប់ពីការផ្ទេរខ្លួនទណ្ឌិត ហើយបើសិនជាអាចអនុវត្តបានត្រូវមានទាំងសេចក្តីរៀបរាប់ពីអនុភាពនៃវាក្យខ័ណ្ឌ ២ មាត្រា ៨ នៃកិច្ចព្រមព្រៀង នេះ ស្តីពីការផ្ទេរទណ្ឌិត

ឃ- ឆន្ទៈរបស់រដ្ឋទទួល ក្នុងការឯកភាពលើការផ្ទេរទណ្ឌិត និងការទទួលរ៉ាប់រងចាត់ចែងអនុវត្តទណ្ឌកម្ម ដែលនៅសេសសល់ចំពោះទណ្ឌិត និង

ង- ពត៌មាន និងឯកសារដទៃទៀត ដែលរដ្ឋផ្ទេរអាចយល់ឃើញថាជាការចាំបាច់ ។

## មាត្រា ៥

## សំណើសុំ និង ការឆ្លើយតប

១- សំណើសុំផ្ទេរទណ្ឌិតត្រូវធ្វើឡើងជាលាយល័ក្ខអក្សរ តាមបែបបទដែលបានកំណត់រួចហើយ និង បញ្ជូនតាមរយៈអាជ្ញាធរកណ្តាលរបស់រដ្ឋជាអ្នកផ្ទេរ តាមផ្លូវការទូតទៅកាន់អាជ្ញាធរកណ្តាលរបស់រដ្ឋដែលត្រូវទទួល ។ ការឆ្លើយតបត្រូវបញ្ជូនតាមបណ្តាញដូចគ្នានេះ ។

២- ចំពោះគោលបំណងនៃកថាខ័ណ្ឌទី ១ នៃមាត្រានេះ អាជ្ញាធរកណ្តាលរបស់ឥណ្ឌា គឺក្រសួងកិច្ចការផ្ទៃក្នុង និង អាជ្ញាធរកណ្តាលរបស់ប្រទេសកម្ពុជា គឺក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា ។

៣- រដ្ឋដែលត្រូវបានគេស្នើសុំ ត្រូវផ្តល់ពត៌មានជាបន្ទាន់ទៅឱ្យរដ្ឋជាអ្នកស្នើអំពីការសំរេចរបស់ខ្លួន ថាតើយល់ព្រមឬក៏មិនយល់ព្រមចំពោះការផ្ទេរទណ្ឌិតនេះ ។

## មាត្រា ៦

## ការយល់ព្រម និង ការបញ្ជាក់ពីការយល់ព្រម

១- រដ្ឋផ្ទេរត្រូវធានាថា ការផ្ទេរនោះគឺធ្វើឡើងដោយមានការយល់ព្រមពីទណ្ឌិតចំពោះការផ្ទេរខ្លួន ដែលស្របតាមកថាខ័ណ្ឌ ១ ចំណុច (ឃ) មាត្រា ៣ នៃកិច្ចព្រមព្រៀងនេះ ត្រូវតែធ្វើឡើងដោយស្ម័គ្រចិត្ត និងដោយការយល់ដឹងពេញលេញ អំពីផលវិបាកនៃច្បាប់តទៅថ្ងៃក្រោយ ។ នីតិវិធីក្នុងការផ្តល់ការយល់ព្រមបែបនេះ និងត្រូវធ្វើទៅតាមច្បាប់របស់រដ្ឋផ្ទេរ ។

២- រដ្ឋផ្ទេរត្រូវបើកលទ្ធភាពផ្តល់ឱកាសអោយរដ្ឋជាអ្នកទទួលដើម្បីបានបញ្ជាក់ថា ការយល់ព្រមនោះត្រូវបានផ្តល់ឱ្យសមស្របទៅតាមល័ក្ខខ័ណ្ឌចែងក្នុងកថាខ័ណ្ឌ ១ នៃមាត្រានេះ ។

## មាត្រា ៧

## ចម្ម័យនៃការផ្ទេរសិទ្ធិរបស់រដ្ឋទទួល

១- អាជ្ញាធរមានសមត្ថកិច្ចរបស់រដ្ឋទទួលត្រូវបន្តអនុវត្តការដាក់ទណ្ឌកម្ម តាមរយៈការបញ្ជាផ្អែកតុលាការ ឬ ផ្អែករដ្ឋបាលតាមដែលច្បាប់ជាតិរបស់ខ្លួនតម្រូវ យោងទៅតាមល័ក្ខខ័ណ្ឌចែងក្នុងមាត្រា ៨ នៃកិច្ចព្រម ព្រៀងនេះ ។

២- ផ្អែកទៅលើបទបញ្ញត្តិចែងក្នុងមាត្រា ១០ នៃកិច្ចព្រមព្រៀងនេះ ការអនុវត្តដាក់ទណ្ឌកម្មនឹងត្រូវគ្រប់គ្រងដោយច្បាប់របស់រដ្ឋទទួល ហើយរដ្ឋនេះតែម្នាក់ឯងមានសមត្ថកិច្ចក្នុងការធ្វើសេចក្តីសំរេចសមស្របនានា ។

## មាត្រា ៨

## ការបន្តអនុវត្តន៍សាលក្រម

១- រដ្ឋទទួលត្រូវអនុវត្តតាមចរិកគតិយុត្តិ និងទម្ងន់ទោស ដែលរដ្ឋផ្ទេរបានសំរេចហើយ ។

២- ទោះជាយ៉ាងណា បើសិនជាសាលក្រមមានចរិកគតិយុត្តិ និងទម្ងន់ទោស ឬ លក្ខណៈទាំងពីរប្រភេទនេះ មិនសមស្របទៅតាមច្បាប់របស់រដ្ឋទទួល ឬ ច្បាប់របស់រដ្ឋទទួលត្រូវការដូច្នោះ រដ្ឋនោះអាចយកលំនាំតាមសាលក្រម ឬ វិធានការដែលមានចែងក្នុងច្បាប់របស់ខ្លួន តាមបទបញ្ជាតុលាការ ឬ នីតិវិធីតាមផ្លូវរដ្ឋបាល ។ ដោយចរិកគតិយុត្តិ និង ទម្ងន់ទោសរបស់វា ការដាក់ទណ្ឌកម្ម ឬ វិធានការនានា ត្រូវធ្វើតាមលទ្ធភាពដែលអាចធ្វើបាន ដើម្បីអោយស៊ីគ្នាជាមួយនឹងការវិនិច្ឆ័យ ដែលរដ្ឋផ្ទេរបានសំរេចហើយ ។ ទោះបីយ៉ាងណា ដោយចរិកគតិយុត្តិ និង ទម្ងន់ទោសរបស់ខ្លួន រដ្ឋទទួលមិនត្រូវបន្ថែមស្ថានទម្ងន់ទោស ទៅលើសាលក្រមដែលត្រូវបានកំណត់រួចហើយនៅក្នុងរដ្ឋផ្ទេរឡើយ ។

## មាត្រា ៩

## ចម្ម័យនៃការទទួលទោសចប់សព្វគ្រប់សំរាប់រដ្ឋផ្ទេរ

កាលណារដ្ឋទទួលបញ្ជាក់ប្រាប់រដ្ឋផ្ទេរតាមវាក្យខ័ណ្ឌ ១(ក) នៃមាត្រា១២ នៃកិច្ចព្រមព្រៀង នេះថាទោសត្រូវបានទទួលចប់សព្វគ្រប់ហើយ ការបញ្ជាក់បែបនេះមានប្រសិទ្ធិភាពនៃការរួចទោសនៅក្នុងរដ្ឋផ្ទេរហើយ ។

## មាត្រា ១០

## ការអនុគ្រោះទោស ការលើកលែងទោស ឬ ការបន្ធូរទោស និង បណ្តឹងសើរើចំពោះការវិនិច្ឆ័យ

១- រដ្ឋផ្ទេរទណ្ឌិត អាចនឹងសំរេចចំពោះពាក្យស្នើសុំអោយសើរើការវិនិច្ឆ័យ ។

២- រដ្ឋណាមួយនៃរដ្ឋហត្ថលេខី អាចផ្តល់ការអនុគ្រោះទោស ការលើកលែងទោស ឬ ការបន្ធូរទោស អនុលោមតាមរដ្ឋធម្មនុញ្ញ និងច្បាប់ផ្សេងៗរបស់ខ្លួន ។

## មាត្រា ១១

## ការបញ្ចប់ការអនុវត្តន៍សាលក្រម

រដ្ឋទទួលត្រូវបញ្ចប់ការអនុវត្តន៍សាលក្រមភ្លាម នៅពេលដែលបានទទួលពត៌មាន ពីរដ្ឋផ្ទេរ ស្តីពីការសំរេច ឬ វិធានការនានា ទាក់ទងទៅនឹងការបញ្ចប់ការអនុវត្តន៍សាលក្រម ។

## មាត្រា ១២

## ពត៌មានស្តីពីការអនុវត្តន៍សាលក្រម

១- រដ្ឋទទួលត្រូវបញ្ជាក់ជូនរដ្ឋផ្ទេរ :

ក- កាលណាការអនុវត្តន៍សាលក្រមត្រូវបានបញ្ចប់ ឬ

ខ- ប្រសិនបើទណ្ឌិតរត់ពីការឃុំឃាំងមុនពេលការអនុវត្តន៍សាលក្រមត្រូវបានបញ្ចប់ ក្នុងករណីបែបនេះ រដ្ឋទទួលត្រូវចាត់វិធានការចាប់ខ្លួនទណ្ឌិត និងដាក់ឱ្យទទួលខុសត្រូវពីការប្រព្រឹត្តបទល្មើសនេះ តាមច្បាប់ពាក់ព័ន្ធរបស់រដ្ឋទទួល ។

២- រដ្ឋទទួលត្រូវផ្តល់របាយការណ៍ពិសេសទាក់ទងទៅនឹងការអនុវត្តន៍សាលក្រម ប្រសិនបើរដ្ឋផ្ទេរមានស្នើសុំ ។

## មាត្រា ១៣

## ដំណើរឆ្លងកាត់

ប្រសិនបើរដ្ឋហត្ថលេខីណាមួយចាត់ការរៀបចំផ្ទេរទណ្ឌិតជាមួយរដ្ឋទីៗ រដ្ឋហត្ថលេខីមួយទៀត ត្រូវសហការ ដើម្បីសុំរលដំណើរឆ្លងកាត់ តាមរយៈទឹកដីនៃទណ្ឌិតដែលត្រូវបានផ្ទេរ លើកលែងតែរដ្ឋហត្ថលេខីមួយ ទៀតនោះ អាចបដិសេធការឆ្លងកាត់ចំពោះទណ្ឌិតណាដែលជាសញ្ជាតិរបស់ខ្លួន ។ រដ្ឋហត្ថលេខីដែលមានបំណងធ្វើការផ្ទេរបែបនេះ ត្រូវជូនដំណឹងជាមុនទៅរដ្ឋហត្ថលេខីមួយទៀត អំពីដំណើរឆ្លងកាត់បែបនេះ ។

### មាត្រា ១៤

### ការចំណាយ

រាល់ការចំណាយក្នុងការអនុវត្តន៍កិច្ចព្រមព្រៀងនេះ ត្រូវជាបន្ទុករបស់រដ្ឋទទួល លើកលែងតែការចំណាយដោយឡែកផ្សេងៗនៅក្នុងទឹកដីរបស់រដ្ឋផ្ញើរ ។ យ៉ាងណាក៏ដោយ រដ្ឋទទួលស្វែងរកឱ្យមានការចំណាយទាំងស្រុង ឬជាចំណែកខ្លះពីទណ្ឌិត ឬ ពីប្រភពដទៃទៀត ។

### មាត្រា ១៥

### ការអនុវត្តន៍នៅលើទឹកដី

១- កិច្ចព្រមព្រៀងនេះត្រូវអនុវត្តចំពោះ :

ក- សាធារណរដ្ឋកូរ៉េ និង

ខ- ព្រះរាជាណាចក្រកម្ពុជា

ព្រមទាំងស្ថាប័ន និង អង្គភាពចំណុះទឹកដីរបស់រដ្ឋហត្ថលេខី ក៏ត្រូវបានបកស្រាយតាមរបៀបដូច្នេះដែរ ។

២- ការអនុវត្តន៍កិច្ចព្រមព្រៀងនេះចំពោះទឹកដីណាមួយ មានចែងវេលាយូរប៉ុន្មាន សមស្របទៅតាម វគ្គខ័ណ្ឌ ១ នៃមាត្រានេះ អាចនឹងត្រូវបញ្ចប់កាលណារដ្ឋហត្ថលេខីណាមួយផ្តល់ដំណឹងពីការអស់សុពលភាព ៦ខែ ជាមុនទៅអោយរដ្ឋហត្ថលេខីមួយទៀត តាមរយៈផ្លូវការទូត ។

### មាត្រា ១៦

### ភាសា

រាល់ការស្នើ និងឯកសារពាក់ព័ន្ធនានា ត្រូវធ្វើទំនាក់ទំនងជាភាសាអង់គ្លេស ។

### មាត្រា ១៧

### វិសាលភាពនៃការអនុវត្តន៍

កិច្ចព្រមព្រៀងនេះ ត្រូវបានយកទៅអនុវត្តលើចំពោះសាលក្រមដែលកំណត់រួចហើយ ទោះជាមុន ឬក្រោយពេលកិច្ចព្រមព្រៀងនេះ ចូលជាធរមានក៏ដោយ ។

### មាត្រា ១៨

### ការធ្វើវិសោធនកម្ម

ការធ្វើវិសោធនកម្ម ឬ ការកែតម្រូវលើកិច្ចព្រមព្រៀងនេះ ដែលបានឯកភាពដោយរដ្ឋហត្ថលេខីទាំងពីរ នឹងមានអនុភាពគតិយុត្តិ កាលណាមានការបញ្ជាក់ដោយការផ្លាស់ប្តូរកំណត់ទូត ។

## មាត្រា ១៩

## អវសានប្បញ្ញត្តិ

១- កិច្ចព្រមព្រៀងនេះជាកម្មវត្ថុនៃការផ្តល់សច្ចាប័ន និងត្រូវចូលជាធរមាន នៅពេលដែលលិខិតតូបករណ៍ នៃការផ្តល់សច្ចាប័នត្រូវបានប្តូរគ្នា ។

២- កិច្ចព្រមព្រៀងនេះនឹងនៅតែមានអនុភាពគតិយុត្តិរហូតដល់ ៦ ខែ បន្ទាប់ពីកាលបរិច្ឆេទដែលរដ្ឋហត្ថលេខីណាមួយ ផ្តល់សេចក្តីជូនដំណឹងជាលាយល័ក្ខអក្សរ ទៅអោយរដ្ឋហត្ថលេខីមួយទៀត អំពីបំណងរបស់ខ្លួនដើម្បីបញ្ចប់កិច្ចព្រមព្រៀងនេះ ។

៣- ដោយមិនចាំបាច់គិតគូរដល់ការបញ្ចប់ កិច្ចព្រមព្រៀងនេះនឹងបន្តអនុវត្តចំពោះការអនុវត្តន៍ដាក់ទណ្ឌកម្មទៅលើទណ្ឌិតដែលត្រូវបានផ្ទេរតាមកិច្ចព្រមព្រៀងនេះ រហូតដល់មុនកាលបរិច្ឆេទដែលការបញ្ចប់ត្រូវចូលជាធរមាន ។

ជាសក្ខីភាព អ្នកចុះហត្ថលេខាជាមន្ត្រីទទួលសិទ្ធិអំណាចត្រឹមត្រូវជាតំណាងរបស់រដ្ឋាភិបាលរៀងៗខ្លួន ត្រូវចុះហត្ថលេខា លើកិច្ចព្រមព្រៀងនេះ ។

ធ្វើនៅញូដែលលី ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ជាពីរច្បាប់ដើម ភាសាខ្មែរ ហិណ្ឌី និងអង់គ្លេស គ្រប់អត្ថបទមានតំលៃស្មើគ្នា ។ ក្នុងករណីមានការបកស្រាយមិនស្របគ្នាអត្ថបទជាភាសាអង់គ្លេស នឹងត្រូវប្រើជាអត្ថបទផ្លូវការ ។

ជំនួសមុខអោយរាជរដ្ឋាភិបាលកម្ពុជា

ហោ ណាំហុង

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីការបរទេសនិង

សហប្រតិបត្តិការអន្តរជាតិ

ជំនួសមុខអោយរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌា

(SHIVRAJ PATIL)

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ